# C138 - Minimum Age Convention, 1973 (No. 138)

*Convention concerning Minimum Age for Admission to Employment (Entry into force: 19 Jun 1976)Adoption: Geneva, 58th ILC session (26 Jun 1973) - Status: Up-to-date instrument (Fundamental Convention).*

## Preamble

The General Conference of the International Labour Organisation,

Having been convened at Geneva by the Governing Body of the International Labour Office, and having met in its Fifty-eighth Session on 6 June 1973, and

Having decided upon the adoption of certain proposals with regard to minimum age for admission to employment, which is the fourth item on the agenda of the session, and

Noting the terms of the Minimum Age (Industry) Convention, 1919, the Minimum Age (Sea) Convention, 1920, the Minimum Age (Agriculture) Convention, 1921, the Minimum Age (Trimmers and Stokers) Convention, 1921, the Minimum Age (Non-Industrial Employment) Convention, 1932, the Minimum Age (Sea) Convention (Revised), 1936, the Minimum Age (Industry) Convention (Revised), 1937, the Minimum Age (Non-Industrial Employment) Convention (Revised), 1937, the Minimum Age (Fishermen) Convention, 1959, and the Minimum Age (Underground Work) Convention, 1965, and

Considering that the time has come to establish a general instrument on the subject, which would gradually replace the existing ones applicable to limited economic sectors, with a view to achieving the total abolition of child labour, and

Having determined that these proposals shall take the form of an international Convention,

adopts this twenty-sixth day of June of the year one thousand nine hundred and seventy-three the following Convention, which may be cited as the Minimum Age Convention, 1973:

## Article 1

Each Member for which this Convention is in force undertakes to pursue a national policy designed to ensure the effective abolition of child labour and to raise progressively the minimum age for admission to employment or work to a level consistent with the fullest physical and mental development of young persons.

## Article 2

1. Each Member which ratifies this Convention shall specify, in a declaration appended to its ratification, a minimum age for admission to employment or work within its territory and on means of transport registered in its territory; subject to Articles 4 to 8 of this Convention, no one under that age shall be admitted to employment or work in any occupation.
2. Each Member which has ratified this Convention may subsequently notify the Director-General of the International Labour Office, by further declarations, that it specifies a minimum age higher than that previously specified.
3. The minimum age specified in pursuance of paragraph 1 of this Article shall not be less than the age of completion of compulsory schooling and, in any case, shall not be less than 15 years.
4. Notwithstanding the provisions of paragraph 3 of this Article, a Member whose economy and educational facilities are insufficiently developed may, after consultation with the organisations of employers and workers concerned, where such exist, initially specify a minimum age of 14 years.
5. Each Member which has specified a minimum age of 14 years in pursuance of the provisions of the preceding paragraph shall include in its reports on the application of this Convention submitted under article 22 of the Constitution of the International Labour Organisation a statement--

- (a) that its reason for doing so subsists; or
- (b) that it renounces its right to avail itself of the provisions in question as from a stated date.

## Article 3

1. The minimum age for admission to any type of employment or work which by its nature or tl circumstances in which it is carried out is likely to jeopardise the health, safety or morals of young perso shall not be less than 18 years.

2. The types of employment or work to which paragraph 1 of this Article applies shall be determined l national laws or regulations or by the competent authority, after consultation with the organisations employers and workers concerned, where such exist.

3. Notwithstanding the provisions of paragraph 1 of this Article, national laws or regulations or tl competent authority may, after consultation with the organisations of employers and workers concerne where such exist, authorise employment or work as from the age of 16 years on condition that the healt safety and morals of the young persons concerned are fully protected and that the young persons ha received adequate specific instruction or vocational training in the relevant branch of activity.

## Article 4

1. In so far as necessary, the competent authority, after consultation with the organisations of employe and workers concerned, where such exist, may exclude from the application of this Convention limit categories of employment or work in respect of which special and substantial problems of application arise

2. Each Member which ratifies this Convention shall list in its first report on the application of tl Convention submitted under article 22 of the Constitution of the International Labour Organisation a categories which may have been excluded in pursuance of paragraph 1 of this Article, giving the reasons f such exclusion, and shall state in subsequent reports the position of its law and practice in respect of tl categories excluded and the extent to which effect has been given or is proposed to be given to tl Convention in respect of such categories.

3. Employment or work covered by Article 3 of this Convention shall not be excluded from the applicatic of the Convention in pursuance of this Article.

## Article 5

1. A Member whose economy and administrative facilities are insufficiently developed may, aft consultation with the organisations of employers and workers concerned, where such exist, initially lim the scope of application of this Convention.

2. Each Member which avails itself of the provisions of paragraph 1 of this Article shall specify, in declaration appended to its ratification, the branches of economic activity or types of undertakings to whic it will apply the provisions of the Convention.

3. The provisions of the Convention shall be applicable as a minimum to the following: mining ar quarrying; manufacturing; construction; electricity, gas and water; sanitary services; transport, storage ar communication; and plantations and other agricultural undertakings mainly producing for commerci purposes, but excluding family and small-scale holdings producing for local consumption and not regular employing hired workers.

4. Any Member which has limited the scope of application of this Convention in pursuance of this Article--

- (a) shall indicate in its reports under Article 22 of the Constitution of the International Labo Organisation the general position as regards the employment or work of young persons and childre in the branches of activity which are excluded from the scope of application of this Convention an any progress which may have been made towards wider application of the provisions of tl Convention;

- (b) may at any time formally extend the scope of application by a declaration addressed to tl Director-General of the International Labour Office.

## Article 6

This Convention does not apply to work done by children and young persons in schools for genera vocational or technical education or in other training institutions, or to work done by persons at least 1 years of age in undertakings, where such work is carried out in accordance with conditions prescribed t the competent authority, after consultation with the organisations of employers and workers concerne where such exist, and is an integral part of--

- (a) a course of education or training for which a school or training institution is primarily responsible;
- (b) a programme of training mainly or entirely in an undertaking, which programme has been approved by the competent authority; or
- (c) aprogramme of guidance or orientation designed to facilitate the choice of an occupation or of a line of training.

### Article 7

1. National laws or regulations may permit the employment or work of persons 13 to 15 years of age on light work which is--
   - (a) not likely to be harmful to their health or development; and
   - (b) not such as to prejudice their attendance at school, their participation in vocational orientation or training programmes approved by the competent authority or their capacity to benefit from the instruction received.

2. National laws or regulations may also permit the employment or work of persons who are at least 15 years of age but have not yet completed their compulsory schooling on work which meets the requirements set forth in sub-paragraphs (a) and (b) of paragraph 1 of this Article.

3. The competent authority shall determine the activities in which employment or work may be permitted under paragraphs 1 and 2 of this Article and shall prescribe the number of hours during which and the conditions in which such employment or work may be undertaken.

4. Notwithstanding the provisions of paragraphs 1 and 2 of this Article, a Member which has availed itself of the provisions of paragraph 4 of Article 2 may, for as long as it continues to do so, substitute the ages 12 and 14 for the ages 13 and 15 in paragraph 1 and the age 14 for the age 15 in paragraph 2 of this Article.

### Article 8

1. After consultation with the organisations of employers and workers concerned, where such exist, the competent authority may, by permits granted in individual cases, allow exceptions to the prohibition of employment or work provided for in Article 2 of this Convention, for such purposes as participation in artistic performances.

2. Permits so granted shall limit the number of hours during which and prescribe the conditions in which employment or work is allowed.

### Article 9

1. All necessary measures, including the provision of appropriate penalties, shall be taken by the competent authority to ensure the effective enforcement of the provisions of this Convention.

2. National laws or regulations or the competent authority shall define the persons responsible for compliance with the provisions giving effect to the Convention.

3. National laws or regulations or the competent authority shall prescribe the registers or other documents which shall be kept and made available by the employer; such registers or documents shall contain the names and ages or dates of birth, duly certified wherever possible, of persons whom he employs or who work for him and who are less than 18 years of age.

### Article 10

1. This Convention revises, on the terms set forth in this Article, the Minimum Age (Industry) Convention, 1919, the Minimum Age (Sea) Convention, 1920, the Minimum Age (Agriculture) Convention, 1921, the Minimum Age (Trimmers and Stokers) Convention, 1921, the Minimum Age (Non-Industrial Employment) Convention, 1932, the Minimum Age (Sea) Convention (Revised), 1936, the Minimum Age (Industry) Convention (Revised), 1937, the Minimum Age (Non-Industrial Employment) Convention (Revised), 1937, the Minimum Age (Fishermen) Convention, 1959, and the Minimum Age (Underground Work) Convention, 1965.

2. The coming into force of this Convention shall not close the Minimum Age (Sea) Convention (Revised), 1936, the Minimum Age (Industry) Convention (Revised), 1937, the Minimum Age (Non-Industrial Employment) Convention (Revised), 1937, the Minimum Age (Fishermen) Convention, 1959, or the Minimum Age (Underground Work) Convention, 1965, to further ratification.

3. The Minimum Age (Industry) Convention, 1919, the Minimum Age (Sea) Convention, 1920, the Minimum Age (Agriculture) Convention, 1921, and the Minimum Age (Trimmers and Stokers) Convention,

1921, shall be closed to further ratification when all the parties thereto have consented to such closing by ratification of this Convention or by a declaration communicated to the Director-General of the International Labour Office.

4. When the obligations of this Convention are accepted--

- (a) by a Member which is a party to the Minimum Age (Industry) Convention (Revised), 1937, and a minimum age of not less than 15 years is specified in pursuance of Article 2 of this Convention, this shall ipso jure involve the immediate denunciation of that Convention,
- (b) in respect of non-industrial employment as defined in the Minimum Age (Non-Industrial Employment) Convention, 1932, by a Member which is a party to that Convention, this shall ipso jure involve the immediate denunciation of that Convention,
- (c) in respect of non-industrial employment as defined in the Minimum Age (Non-Industrial Employment) Convention (Revised), 1937, by a Member which is a party to that Convention, and a minimum age of not less than 15 years is specified in pursuance of Article 2 of this Convention, this shall ipso jure involve the immediate denunciation of that Convention,
- (d) in respect of maritime employment, by a Member which is a party to the Minimum Age (Sea) Convention (Revised), 1936, and a minimum age of not less than 15 years is specified in pursuance of Article 2 of this Convention or the Member specifies that Article 3 of this Convention applies to maritime employment, this shall ipso jure involve the immediate denunciation of that Convention,
- (e) in respect of employment in maritime fishing, by a Member which is a party to the Minimum Age (Fishermen) Convention, 1959, and a minimum age of not less than 15 years is specified in pursuance of Article 2 of this Convention or the Member specifies that Article 3 of this Convention applies to employment in maritime fishing, this shall ipso jure involve the immediate denunciation of that Convention,
- (f) by a Member which is a party to the Minimum Age (Underground Work) Convention, 1965, and a minimum age of not less than the age specified in pursuance of that Convention is specified in pursuance of Article 2 of this Convention or the Member specifies that such an age applies to employment underground in mines in virtue of Article 3 of this Convention, this shall ipso jure involve the immediate denunciation of that Convention,

if and when this Convention shall have come into force.

5. Acceptance of the obligations of this Convention--

- (a) shall involve the denunciation of the Minimum Age (Industry) Convention, 1919, in accordance with Article 12 thereof,
- (b) in respect of agriculture shall involve the denunciation of the Minimum Age (Agriculture) Convention, 1921, in accordance with Article 9 thereof,
- (c) in respect of maritime employment shall involve the denunciation of the Minimum Age (Sea) Convention, 1920, in accordance with Article 10 thereof, and of the Minimum Age (Trimmers and Stokers) Convention, 1921, in accordance with Article 12 thereof,

if and when this Convention shall have come into force.

## *Article 11*

The formal ratifications of this Convention shall be communicated to the Director-General of the International Labour Office for registration.

## *Article 12*

1. This Convention shall be binding only upon those Members of the International Labour Organisation whose ratifications have been registered with the Director-General.

2. It shall come into force twelve months after the date on which the ratifications of two Members have been registered with the Director-General.

3. Thereafter, this Convention shall come into force for any Member twelve months after the date on which its ratifications has been registered.

## Article 13

1. A Member which has ratified this Convention may denounce it after the expiration of ten years from the date on which the Convention first comes into force, by an act communicated to the Director-General of the International Labour Office for registration. Such denunciation shall not take effect until one year after the date on which it is registered.

2. Each Member which has ratified this Convention and which does not, within the year following the expiration of the period of ten years mentioned in the preceding paragraph, exercise the right of denunciation provided for in this Article, will be bound for another period of ten years and, thereafter, may denounce this Convention at the expiration of each period of ten years under the terms provided for in this Article.

## Article 14

1. The Director-General of the International Labour Office shall notify all Members of the International Labour Organisation of the registration of all ratifications and denunciations communicated to him by the Members of the Organisation.

2. When notifying the Members of the Organisation of the registration of the second ratification communicated to him, the Director-General shall draw the attention of the Members of the Organisation to the date upon which the Convention will come into force.

## Article 15

The Director-General of the International Labour Office shall communicate to the Secretary-General of the United Nations for registration in accordance with Article 102 of the Charter of the United Nations full particulars of all ratifications and acts of denunciation registered by him in accordance with the provisions of the preceding Articles.

## Article 16

At such times as it may consider necessary the Governing Body of the International Labour Office shall present to the General Conference a report on the working of this Convention and shall examine the desirability of placing on the agenda of the Conference the question of its revision in whole or in part.

## Article 17

1. Should the Conference adopt a new Convention revising this Convention in whole or in part, then, unless the new Convention otherwise provides:

- (a) the ratification by a Member of the new revising Convention shall ipso jure involve the immediate denunciation of this Convention, notwithstanding the provisions of Article 13 above, if and when the new revising Convention shall have come into force;
- (b) as from the date when the new revising Convention comes into force this Convention shall cease to be open to ratification by the Members.

2. This Convention shall in any case remain in force in its actual form and content for those Members which have ratified it but have not ratified the revising Convention.

## Article 18

The English and French versions of the text of this Convention are equally authoritative.

# អនុសញ្ញាលេខ ១៣៨
# ស្តីពី
# ការកំរិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការងារ[១]

## សន្និសីទសាកលនៃអង្គការការងារអន្តរជាតិ

ត្រូវបានកោះប្រជុំនៅទីក្រុងហ្សឺណែវដោយក្រុមប្រឹក្សាភិបាលនៃការិយាល័យអន្តរជាតិខាងការងារ និងបានបើកសម័យប្រជុំលើកទីហាសិបប្រាំបីរបស់ខ្លួននាថ្ងៃទី ៦ មិថុនា ឆ្នាំ ១៩៧៣, និង

បានសំរេចយល់ព្រមដាក់បញ្ចូលសំណើមួយចំនួនស្តីពីអាយុអប្បបរមាដែលត្រូវអនុញ្ញាតឱ្យចូលធ្វើការទៅក្នុងរបៀបវារៈនៃសម័យប្រជុំ ត្រង់ "ខ" ទីបួន, និង

បានឃើញខ្លឹមសារនៃអនុសញ្ញាឆ្នាំ ១៩១៩ ស្តីពីអាយុអប្បបរមា (សម្រាប់សហគ្រាសឧស្សាហកម្ម)។ អនុសញ្ញាឆ្នាំ១៩២០ ស្តីពីអាយុអប្បបរមា (សម្រាប់ការងារនៅសមុទ្រ) អនុសញ្ញាឆ្នាំ១៩២១ ស្តីពីអាយុអប្បបរមា (សម្រាប់ការងារកសិកម្ម) អនុសញ្ញាឆ្នាំ១៩២១ ស្តីពីអាយុអប្បបរមា (សម្រាប់ការងារថែរក្សា និងដុតភ្លើងឡចំហាយ ឬម៉ាស៊ីនចំហាយ) អនុសញ្ញាឆ្នាំ១៩៣២ ស្តីពីអាយុអប្បបរមា (សម្រាប់ការងារមិនមែនឧស្សាហកម្ម) អនុសញ្ញាឆ្នាំ១៩៣៦ (អនុសញ្ញាពិនិត្យជាថ្មី) ស្តីពីអាយុអប្បបរមា (សម្រាប់ការងារនៅសមុទ្រ) អនុសញ្ញាឆ្នាំ១៩៣៧ (ពិនិត្យជាថ្មី) ស្តីពីអាយុអប្បបរមា (សម្រាប់ការងារឧស្សាហកម្ម) អនុសញ្ញាឆ្នាំ១៩៣៧ (ពិនិត្យជាថ្មី) ស្តីពីអាយុអប្បបរមា (សម្រាប់ការងារមិនមែនឧស្សាហកម្ម) អនុសញ្ញាឆ្នាំ១៩៥៩ ស្តីពីអាយុអប្បបរមា (សម្រាប់អ្នកនេសាទ) និងអនុសញ្ញាឆ្នាំ១៩៦៥ ស្តីពីអាយុអប្បបរមា (សម្រាប់ការងារក្រោមដី), និង

បានពិនិត្យឃើញថាពេលនេះ គឺដល់ពេលដែលត្រូវបង្កើតលិខិតូបករណ៍ទូទៅមួយទាក់ទងនឹងប្រធានបទស្តីពីការកំរិតអាយុអប្បបរមានេះ ហើយដែលជាបណ្តើរៗអាចមកជំនួសគោលការណ៍ជាធរមានទៅតាមកំរិតនៃផ្នែកសេដ្ឋកិច្ចនានា ក្នុងគោលបំណងសំដៅឆ្ពោះទៅដល់ការលុបបំបាត់ទាំងស្រុងនៃការងារកុមារ, និង

បានសំរេចជាសំណើទាំងនេះត្រូវតែតាក់តែងចងក្រងជាអនុសញ្ញាអន្តរជាតិមួយ។

---

១. កាលបរិច្ឆេទចូលជាធរមាន : ១៩ មិថុនា ១៩៧៦

អនុម័តនៅថ្ងៃទីម្ភៃប្រាំមួយ ខែមិថុនា ឆ្នាំមួយពាន់ប្រាំបួនរយចិតសិបបី ចំពោះអនុសញ្ញាជាបន្តទៅនេះ ដែលមានឈ្មោះថាអនុសញ្ញាឆ្នាំ១៩៧៣ ស្តីពីការកំរិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការងារៈ

## មាត្រា ១

ចំពោះប្រទេសជាសមាជិកណាដែលអនុសញ្ញានេះបានចូលជាធរមានរួចហើយ គួរព្រមព្រៀងធ្វើគោលនយោបាយជាតិមួយដើម្បីសំដៅធានាចំពោះការលុបបំបាត់ការងារកុមារឱ្យបានប្រកបដោយប្រសិទ្ធិភាព និងសំដៅបង្កើតឱ្យកាន់តែខ្ពស់ឡើងនូវកំរិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការងារ ឬការចូលប្រកបមុខរបរឱ្យបានសមស្របតាមកំរិតនៃការរីកលូតលាស់ពេញលេញទាំងខាងកម្លាំងកាយ និងសតិបញ្ញារបស់ក្មេង។

## មាត្រា ២

១. ប្រទេសជាសមាជិកណាមួយដែលផ្តល់សច្ចាប័នចំពោះអនុសញ្ញានេះ ត្រូវបញ្ជាក់បង្ហាញក្នុងសេចក្តីប្រកាសបន្ថែមលើការផ្តល់សច្ចាប័នរបស់ខ្លួន អំពីកំរិតអាយុអប្បបរមាដែលអនុញ្ញាតឱ្យចូលធ្វើការងារ ឬប្រកបមុខរបរ និងដែលអនុញ្ញាតឱ្យធ្វើការនៅតាមយានដឹកជញ្ជូននានានៅក្នុងដែនដីរបស់ខ្លួន។ លើកលែងតែបទបញ្ញត្តិដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៨ នៃអនុសញ្ញានេះ គ្មានជនណាម្នាក់ដែលមានអាយុក្រោមការកំរិតនោះអាចត្រូវបានគេប្រើឱ្យប្រកបការងារនៅក្នុងមុខរបរណាក៏ដោយ។

២. ប្រទេសជាសមាជិកណាមួយដែលផ្តល់សច្ចាប័នអនុសញ្ញានេះ ត្រូវជូនដំណឹងទៅអគ្គនាយកការិយាល័យអន្តរជាតិនៃការងារជាបន្តបន្ទាប់តាមរយៈសេចក្តីប្រកាសបន្ថែម ដែលក្នុងសេចក្តីប្រកាសនោះមានបញ្ជាក់អំពីកំរិតអាយុអប្បបរមាដែលកាន់តែខ្ពស់ជាងការកំរិតកាលពីលើកដំបូង។

៣. កំរិតអាយុអប្បបរមាដូចមានចង្អុលក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះមិនត្រូវតិចជាងអាយុបញ្ចប់ការសិក្សាជាកាតព្វកិច្ច។ ម៉្យាងទៀតទោះក្នុងករណីណាក៏ដោយ កំរិតអាយុអប្បបរមានេះមិនត្រូវតិចជាង ១៥ ឆ្នាំទេ។

៤. ដោយមិនគិតដល់បទបញ្ញត្តិនៃវាក្យខ័ណ្ឌទី ៣ នៃមាត្រានេះ ប្រទេសជាសមាជិកណាដែលមានសេដ្ឋកិច្ច និងរចនាសម្ព័ន្ធអប់រំមិនទាន់លូតលាស់ បន្ទាប់ពីពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអង្គការកម្មករនិយោជិតពាក់ព័ន្ធ ប្រសិនបើមានអង្គការទាំងនេះ អាចកំរិតអាយុអប្បបរមាជាបឋមត្រឹម ១៤ ឆ្នាំ សិនក៏បាន។

៥. ប្រទេសជាសមាជិកណាដែលបានកំរិតអាយុអប្បបរមាត្រឹម ១៤ ឆ្នាំ ដោយយោងតាមបទបញ្ញត្តិក្នុងវាក្យខ័ណ្ឌខាងលើ អនុលោមតាមមាត្រា ២២ នៃធម្មនុញ្ញរបស់អង្គការអន្តរ

ជាតិខាងការងារ ប្រទេសជាសមាជិកនោះត្រូវធ្វើរបាយការណ៍អំពីការអនុវត្តន៍អនុសញ្ញានេះ ដោយមានដាក់បញ្ចូលនូវសេចក្ដីថ្លែងការណ៍បញ្ជាក់អំពី៖

(ក) មូលហេតុនៃការកំរិតដូច្នេះ គឺដើម្បីធ្វើឱ្យមានលទ្ធភាពអាចចិញ្ចឹមជីវិតបាន។

(ខ) ការបោះបង់សិទ្ធិរបស់ខ្លួនក្នុងការប្រើប្រាស់បទបញ្ញត្តិនេះចាប់ពីកាលបរិច្ឆេទដែលបានប្រកាសរួចមក។

## មាត្រា ៣

១. ចំពោះមុខរបរ ឬការងារណាដែលដោយសារប្រភេទ ឬស្ថានភាពនៃមុនរបរ ឬការងារនោះនៅពេលដែលធ្វើទៅនាំឱ្យមានការប៉ះពាល់ដល់សុខភាព សុវត្ថិភាព ឬសតិបញ្ញារបស់ក្មេង អាយុអប្បបរមាដែលអាចឱ្យចូលបំរើក្នុងមុខរបរ ឬការងារទាំងនោះត្រូវកំរិតមិនឱ្យតិចជាង ១៨ ឆ្នាំឡើយ។

២. ប្រភេទមុខរបរ ឬការងារដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ត្រូវកំណត់ដោយច្បាប់ ឬបទបញ្ជានានារបស់ជាតិ ឬក៏ត្រូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយអង្គការរបស់និយោជក និងអង្គការកម្មករនិយោជិតសាមីប្រសិនបើមានអង្គការទាំងនេះ។

៣. ដោយមិនគិតដល់បទបញ្ញត្តិនៃវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអង្គការកម្មករនិយោជិតសាមី ក្នុងករណីដែលមានអង្គការទាំងនេះ ច្បាប់ ឬបទបញ្ជានានារបស់ជាតិ ឬក៏អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឱ្យមានមុខរបរ ឬការងារសម្រាប់ក្មេងដែលមានអាយុត្រឹម ១៦ ឆ្នាំ ក្នុងលក្ខខណ្ឌដែលថាក្មេងទាំងនោះ ត្រូវបានទទួលការការពារយ៉ាងពេញលេញខាងផ្នែកសុខភាព សុវត្ថិភាព ឬសតិបញ្ញា ព្រមទាំងទទួលនូវការហ្វឹកហ្វឺនយ៉ាងត្រឹមត្រូវចំពោះវិជ្ជាជីវៈដែលពាក់ព័ន្ធ។

## មាត្រា ៤

១. ប្រសិនបើមានការចាំបាច់ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអង្គការកម្មករនិយោជិតសាមី ក្នុងករណីដែលមានអង្គការទាំងនោះ អាជ្ញាធរមានសមត្ថកិច្ចអាចវៀរលែងមិនអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះចំពោះប្រភេទកំណត់នៃមុខរបរ ឬការងារនានា ដែលកាលណាការអនុវត្តន៍នេះអាចនាំឱ្យមានការលំបាកផ្សេងៗកើតឡើង។

២. ប្រទេសជាសមាជិកណាដែលឱ្យសច្ចាប័នអនុសញ្ញានេះ ត្រូវធ្វើបញ្ជីប្រភេទកំណត់នៃមុខរបរ ឬការងារដែលត្រូវលើកលែង ដូចដែលមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ភ្ជាប់ជាមួយនឹងរបាយការណ៍លើកទីមួយរបស់ខ្លួន ស្ដីពីការអនុវត្តន៍អនុសញ្ញានេះអនុលោមតាមមាត្រា ២២ នៃធម្មនុញ្ញរបស់អង្គការអន្តរជាតិខាងការងារ ដោយមានធ្វើការបញ្ជាក់ពី

មូលហេតុនៃការលើកលែងទាំងនោះផង។ ម៉្យាងទៀត ប្រទេសជាសមាជិកនោះ ក៏ត្រូវបញ្ជាក់នៅក្នុងរបាយការណ៍បន្តបន្ទាប់របស់ខ្លួនផងដែរនូវស្ថានភាពនានានៃច្បាប់ និងការអនុវត្តន៍ជាក់ស្តែងនៅក្នុងប្រទេសពាក់ព័ន្ធនឹងប្រភេទកំណត់នៃមុខរបរ ឬការងារដែលត្រូវលើកលែងព្រមទាំងពាក់ព័ន្ធនឹងវិធានការ ដែលចំពោះវិធានការនេះនាំឱ្យមានផលវិបាកកើតឡើងឬក៏ត្រូវស្នើចំពោះអនុសញ្ញាឱ្យធ្វើការកំណត់ទាក់ទងនឹងប្រភេទកំណត់នៃមុខរបរ ឬការងារដែលត្រូវលើកលែងទាំងនោះ។

៣. មុខរបរ ឬការងារដែលត្រូវគ្របដណ្តប់ដោយមាត្រា ៣ នៃអនុសញ្ញានេះមិនត្រូវបានវៀរលែងចំពោះការអនុវត្តន៍បទបញ្ញត្តិក្នុងមាត្រានេះទេ។

## មាត្រា ៥

១. ចំពោះប្រទេសជាសមាជិកណាដែលលទ្ធភាពខាងសេដ្ឋកិច្ច និងរដ្ឋបាលនៅមានកង្វះខាត ប្រទេសនោះអាចកំរិតព្រំដែននៃដែនអនុវត្តរបស់អនុសញ្ញានេះបាន បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអង្គការកម្មករនិយោជិតសាមី ប្រសិនបើមានអង្គការទាំងនោះ។

២. ប្រទេសជាសមាជិកណាដែលបានអនុវត្តតាមបទបញ្ញត្តិនៃវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ត្រូវបញ្ជាក់នៅក្នុងសេចក្តីប្រកាសបន្ថែមលើការផ្តល់សច្ចាប័នរបស់ខ្លួនអំពីផ្នែកសកម្មភាពសេដ្ឋកិច្ច ឬប្រភេទសហគ្រាសនានាដែលត្រូវអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះ។

៣. បទបញ្ញត្តិនៃអនុសញ្ញានេះត្រូវអនុវត្តឱ្យបានជាអប្បបរមាចំពោះអាជីវកម្មដូចតទៅ៖ អណ្តូងរ៉ែ និងការដ្ឋានវាយថ្ម កម្មន្តសាល សំណង់ អគ្គិសនី ចំការ និងអាជីវកម្មកសិកម្មដទៃទៀតដែលការផលិតជាសំខាន់ គឺសម្រាប់គោលដៅពាណិជ្ជកម្ម លើកលែងតែអាជីវកម្មដែលមានលក្ខណៈជាគ្រួសារ និងអាជីវកម្មដែលមានទំហំតូចផលិតសម្រាប់តែសេចក្តីត្រូវការក្នុងភូមិស្រុក ហើយមិនមានប្រើប្រាស់កម្មករនិយោជិតជាទៀងទាត់។

៤. ប្រទេសជាសមាជិកណាមួយដែលបានកំរិតព្រំដែននៃដែនអនុវត្តនៃអនុសញ្ញានេះដោយអនុលោមតាមបទបញ្ញត្តិក្នុងមាត្រានេះ ត្រូវ៖

(ក) បង្ហាញនៅក្នុងរបាយការណ៍យោងតាមមាត្រា ២២ នៃធម្មនុញ្ញរបស់អង្គការអន្តរជាតិខាងការងារនូវស្ថានភាពទូទៅនៃមុខរបរ ឬការងាររបស់ក្មេងជំទង់ និងកុមារនៅក្នុងផ្នែកសកម្មភាពសេដ្ឋកិច្ចដែលមិនរាប់ចូលជាមួយដែនអនុវត្តនៃអនុសញ្ញានេះ ព្រមទាំងអំពីការរីកចំរើននានាដែលអាចឈានទៅពង្រីកការអនុវត្តន៍ បទបញ្ញត្តិនៃអនុសញ្ញានេះផង។

(ខ) អាចពង្រីកដែនអនុវត្តនៃអនុសញ្ញានេះបានគ្រប់ពេល តាមរយៈការធ្វើសេចក្តីប្រកាសជាផ្លូវការមួយផ្ញើជូនទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារ។

## មាត្រា ៦

អនុសញ្ញានេះមិនអនុវត្តចំពោះការងារដែលធ្វើដោយក្មេង ឬមនុស្សជំទង់នៅក្នុងគ្រឹះស្ថានសិក្សាចំណេះទូទៅ នៅក្នុងសាលាវិជ្ជាជីវៈ ឬសាលាបច្ចេកទេស ឬការងារនៅក្នុងសហគ្រាសរបស់ក្មេងដែលមានអាយុយ៉ាងតិច ១៤ ឆ្នាំឡើយ ប្រសិនបើការងារទាំងនេះត្រូវបានអនុវត្តដោយអនុលោមតាមលក្ខខណ្ឌនានាដែលបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអង្គការនិយោជក ឬអង្គការកម្មករនិយោជិតសាមីប្រសិនបើមានអង្គការទាំងនេះ ហើយដែលការងារនេះ គឺជាផ្នែកបតិដ្ឋាននៃៈ

(ក) វគ្គនៃការអប់រំ ឬការបណ្តុះបណ្តាលដែលភាគច្រើនត្រូវទទួលភារៈដោយសាលា ឬស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈ។

(ខ) កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈមួយដែលធ្វើឡើងដោយភាគច្រើន ឬទាំងស្រុងនៅក្នុងសហគ្រាសមួយ ហើយដែលកម្មវិធីនេះត្រូវបានទទួលការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ច។

(គ) កម្មវិធីណែនាំ ឬតម្រង់ទិសវិជ្ជាជីវៈដែលធ្វើឡើងដើម្បីសម្រួលដល់ការជ្រើសរើសមុខរបរណាមួយ ឬជ្រើសរើសមុខវិជ្ជាជីវៈណាមួយ។

## មាត្រា ៧

១. ច្បាប់ ឬបទបញ្ញត្តិជាតិអាចអនុញ្ញាតដល់មុខរបរ ឬការងារនៃក្មេងដែលមានអាយុពី ១៣ ដល់ ១៥ ឆ្នាំ ចំពោះការងារស្រាលៗ ដែលមានលក្ខខណ្ឌដូចខាងក្រោមៈ

(ក) ការងារដែលមិនមានគ្រោះថ្នាក់ចំពោះសុខភាព និងការអភិវឌ្ឍន៍នៃក្មេង។

(ខ) ការងារណាដែលមិនធ្វើឱ្យប៉ះពាល់ខូចខាតដល់ការរៀនសូត្រ ការចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលតម្រង់ទិសវិជ្ជាជីវៈដែលបានយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ច ឬក៏ការងារដែលមិនបណ្តាលឱ្យប៉ះពាល់ដល់សម្បទាក្នុងការចាប់យកវិជ្ជាជីវៈរបស់ក្មេង។

២. ច្បាប់ ឬបទបញ្ញត្តិជាតិ ក៏អាចអនុញ្ញាតដល់មុខរបរ ឬការងារនៃក្មេងដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើង ប៉ុន្តែមិនទាន់បានបញ្ចប់កាតព្វកិច្ចសិក្សារបស់ខ្លួននៅឡើយ ចំពោះតែការងារដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃចំណុច (ក) និង (ខ) នៃកថាខណ្ឌ ១ នៃមាត្រា នេះ។

៣. អាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់នូវសកម្មភាពទាំងឡាយណាដែលក្នុងនោះមុខរបរ ឬការងារអាចត្រូវបានទទួលការអនុញ្ញាតក្រោមបទបញ្ញត្តិនៃកថាខណ្ឌ ១ និង ២ នៃមាត្រានេះ ព្រមទាំងត្រូវកំណត់ចំនួនម៉ោង និងលក្ខខណ្ឌនានាចំពោះមុខរបរ ឬការងារទាំងនេះត្រូវប្រព្រឹត្ត។

៤. ដោយមិនគិតដល់បទបញ្ញត្តិនៃកថាខណ្ឌ ១ និង ២ នៃមាត្រានេះ ប្រទេសជាសមាជិកណាដែលយល់ថាបទបញ្ញត្តិក្នុងកថាខណ្ឌ ៤ នៃមាត្រា ២ នៅមានសារៈសំខាន់ដែលខ្លួនចាំបាច់ត្រូវបន្តអនុវត្តតទៅទៀត អាចយកអាយុពី ១២ ដល់ ១៣ ឆ្នាំ ជំនួសការកំណត់អាយុពី ១៣ ទៅ ១៥ ឆ្នាំ ដែលមានចែងនៅក្នុងកថាខណ្ឌ ១ និងយកអាយុ ១៤ ឆ្នាំ ជំនួសការកំណត់អាយុ ១៥ ឆ្នាំ ដែលមានចែងនៅក្នុងកថាខណ្ឌ ២ នៃមាត្រានេះ។

## មាត្រា ៨

១. ប្រសិនបើមានវត្តមានអង្គការនិយោជក ឬអង្គការកម្មករនិយោជិតសាមី បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអង្គការទាំងនេះមក អាជ្ញាធរមានសមត្ថកិច្ចតាមរយៈការផ្ដល់ការអនុញ្ញាតជាបុគ្គល អាចលើកលែងចំពោះការហាមឃាត់លើមុខរបរ ឬការងារដូចដែលបានចែងក្នុងមាត្រា ២ នៃអនុសញ្ញានេះ ដែលការងារនោះធ្វើឡើងសម្រាប់តែការចូលរួមនៅក្នុងការសំដែងសិល្បៈប៉ុណ្ណោះ។

២. ការផ្ដល់នូវការអនុញ្ញាតដូច្នេះ ត្រូវមានកំរិតចំនួនម៉ោង និងកំណត់លក្ខខណ្ឌសម្រាប់មុខរបរ ឬការងារទាំងនោះផង។

## មាត្រា ៩

១. អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់គ្រប់វិធានការចាំបាច់ទាំងអស់ គិតទាំងការផ្ដន្ទាទោសសមស្របផង ដើម្បីធានាអនុវត្តប្រកបដោយប្រសិទ្ធភាពនូវបទបញ្ញត្តិនៃអនុសញ្ញានេះ។

២. ច្បាប់ ឬបទបញ្ញត្តិជាតិ ឬអាជ្ញាធរមានសមត្ថកិច្ច ត្រូវកំណត់ឱ្យមានអ្នកទទួលខុសត្រូវសម្រាប់ការអនុវត្តន៍បទបញ្ញត្តិដើម្បីធ្វើឱ្យមានប្រសិទ្ធភាពនូវអនុសញ្ញានេះ។

៣. ច្បាប់ ឬបទបញ្ញត្តិជាតិ ឬអាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់ឱ្យមានសៀវភៅបញ្ជី ឬឯកសារផ្សេងដទៃទៀត ដែលនិយោជកត្រូវមាន និងរក្សាទុក។ សៀវភៅបញ្ជី ឬឯកសារទាំងនេះត្រូវមានចុះឈ្មោះ អាយុ ឬថ្ងៃខែកំណើតរបស់ជនដែលមានអាយុតិចជាង ១៨ ឆ្នាំ ដែលខ្លួនបានប្រើឱ្យធ្វើការ ដោយមានការបញ្ជាក់យ៉ាងត្រឹមត្រូវតាមដែលអាចធ្វើបាន។

## មាត្រា ១០

១. អនុសញ្ញានេះធ្វើការពិនិត្យឡើងវិញ នូវអនុសញ្ញាឆ្នាំ១៩១៩ ស្ដីពីអាយុអប្បបរមា (ក្នុងឧស្សាហកម្ម) អនុសញ្ញាឆ្នាំ១៩២០ ស្ដីពីអាយុអប្បបរមា (ការងារក្នុងសមុទ្រ) អនុសញ្ញាឆ្នាំ១៩២១ ស្ដីពីអាយុអប្បបរមា (ក្នុងវិស័យកសិកម្ម) អនុសញ្ញាឆ្នាំ១៩២១ ស្ដីពីអាយុអប្បបរមា (សម្រាប់អ្នករៀបចំបន្ទុកនាវា និងអ្នកដុតឡក្នុងនាវា) អនុសញ្ញាឆ្នាំ១៩៣២ ស្ដីពីអាយុអប្បបរមា(ការងារមិនមែនឧស្សាហកម្ម) អនុសញ្ញាឆ្នាំ១៩៦៣ (ពិនិត្យឡើងវិញ) ស្ដីពីអាយុអប្បបរមា (ការងារសមុទ្រ) អនុសញ្ញាឆ្នាំ១៩៣៧ (ពិនិត្យឡើងវិញ) ស្ដីពីអាយុអប្បបរមា

(ការងារឧស្សាហកម្ម) អនុសញ្ញាឆ្នាំ១៩៥៩ ស្តីពីអាយុអប្បបរមា (សម្រាប់អ្នកនេសាទ) អនុសញ្ញាឆ្នាំ១៩៦៥ ស្តីពីអាយុអប្បបរមា (ការងារក្រោមដី)។

២. ការចូលជាធរមាននៃអនុសញ្ញានេះមិនបិទការផ្តល់សច្ចាប័នតទៅទៀត ចំពោះ អនុសញ្ញាឆ្នាំ១៩៣៦ (ពិនិត្យឡើងវិញ) ស្តីពីអាយុអប្បបរមា (ការងារសមុទ្រ) អនុសញ្ញាឆ្នាំ ១៩៣៧ (ពិនិត្យឡើងវិញ) ស្តីពីអាយុអប្បបរមា (ឧស្សាហកម្ម) អនុសញ្ញាឆ្នាំ១៩៣៧ (ពិនិត្យ ឡើងវិញ) ស្តីពីអាយុអប្បបរមា (ការងារមិនមែនឧស្សាហកម្ម) អនុសញ្ញាឆ្នាំ១៩៥៩ ស្តីពីអាយុ អប្បបរមា (អ្នកនេសាទ) និងអនុសញ្ញាឆ្នាំ១៩៦៥ ស្តីពីអាយុអប្បបរមា (ការងារក្រោមដី)។

៣. អនុសញ្ញាឆ្នាំ១៩១៩ ស្តីពីអាយុអប្បបរមា (ក្នុងឧស្សាហកម្ម) អនុសញ្ញាឆ្នាំ១៩២០ ស្តីពីអាយុអប្បបរមា (ការងារសមុទ្រ) អនុសញ្ញាឆ្នាំ១៩២១ ស្តីពីអាយុអប្បបរមា (ក្នុងវិស័យ កសិកម្ម) អនុសញ្ញាឆ្នាំ១៩២១ ស្តីពីអាយុអប្បបរមា (អ្នករៀបចំទុកដាក់ និងអ្នកដុតឡនាវា) ត្រូវបិទឈប់ឱ្យធ្វើសច្ចាប័នបន្ត នៅពេលណាដែលរាល់ភាគីទាំងអស់បានយល់ព្រមចំពោះ ការបិទបែបនេះដោយការផ្តល់សច្ចាប័នចំពោះអនុសញ្ញានេះ ឬដោយការធ្វើសេចក្តីប្រកាស ជូនដំណឹង ទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារ។

៤. នៅពេលដែលអនុសញ្ញានេះចូលជាធរមាន កាតព្វកិច្ចនៃអនុសញ្ញានេះត្រូវបាន ទទួលយល់ព្រម៖

(ក) ដោយសមាជិកណាមួយដែលជាដៃគូនៃអនុសញ្ញាឆ្នាំ១៩៣៧ (ពិនិត្យឡើងវិញ) ស្តីពីអាយុអប្បបរមា (ឧស្សាហកម្ម) និងដោយយោងតាមការកំរិតអាយុ អប្បបរមាមិនតិចជាង ១៥ ឆ្នាំ ដូចមានចែងក្នុងមាត្រា ២ នៃអនុសញ្ញានេះ ប្រទេសជាសមាជិកនោះត្រូវចាត់ទុកដោយពេញច្បាប់ថាបានធ្វើអប្បជិបត្តិកម្ម លើអនុសញ្ញាឆ្នាំ១៩៣៧ នោះ។

(ខ) ដោយប្រទេសជាសមាជិកណាមួយដែលជាដៃគូនៃអនុសញ្ញាឆ្នាំ១៩៣២ ដែល ស្តីពីអាយុអប្បបរមា (ក្នុងវិស័យមិនមែនឧស្សាហកម្ម) នោះ ប្រទេសជាសមាជិក នេះត្រូវចាត់ដោយពេញច្បាប់ថាបានធ្វើអប្បជិបត្តិកម្មលើអនុសញ្ញាឆ្នាំ១៩៣២។

(គ) ចំពោះមុខរបរដែលមិនមែនជាឧស្សាហកម្ម ដែលមានកំណត់អាយុអប្បបរមា នៅក្នុងអនុសញ្ញាឆ្នាំ១៩៣៧ (អនុសញ្ញាពិនិត្យឡើវិញ) គឺកាតព្វកិច្ចដែលបាន យល់ព្រមដោយប្រទេសជាសមាជិកណាមួយដែលជាដៃគូនឹងអនុសញ្ញានោះ និងដោយយោងតាមការកំរិតអាយុអប្បបរមាមិនតិចជាង ១៥ ឆ្នាំ ដូចមានចែង ក្នុងមាត្រា ២ នៃអនុសញ្ញានេះ ប្រទេសនោះនឹងត្រូវចាត់ទុកដោយពេញច្បាប់ ថាបានធ្វើអប្បជិបត្តិកម្មចំពោះអនុសញ្ញាឆ្នាំ១៩៣៧។

(ឃ) ចំពោះមុខរបរនៅសមុទ្រ គឺកាតព្វកិច្ចដែលបានយល់ព្រមដោយប្រទេសជា សមាជិកណាមួយដែលជាដៃគូនឹងអនុសញ្ញាឆ្នាំ១៩៣៦ (អនុសញ្ញាបុនរាព្រឹត្ត)

ដែលស្ដីពីអាយុអប្បបរមា (ការងារក្នុងសមុទ្រ) និងដោយអនុលោមតាមការកំរិតអាយុអប្បបរមាមិនតិចជាង ១៥ ឆ្នាំ ដូចមានចែងក្នុងមាត្រា ២ នៃអនុសញ្ញានេះ ឬបើប្រទេសសមាជិកនោះកំណត់យកមាត្រា ៣ នៃអនុសញ្ញានេះដើម្បីអនុវត្តការងារនៅក្នុងសមុទ្រ ប្រទេសនោះនឹងត្រូវចាត់ដោយពេញច្បាប់ថាបានធ្វើអប្បដិបត្តិកម្ម ចំពោះអនុសញ្ញាខាងលើ។

(ង) ចំពោះការងារនេសាទសមុទ្រ គឺកាតព្វកិច្ចដែលបានយល់ព្រមដោយប្រទេសជាសមាជិកណាមួយដែលជាដៃគូអនុសញ្ញាឆ្នាំ១៩៥៩ ស្ដីពីអាយុអប្បបរមា (ការងារនេសាទសមុទ្រ) និងដោយផ្អែកតាមការកំរិតអាយុអប្បបរមាមិនតិចជាង ១៥ ឆ្នាំ ដូចដែលមានចែងក្នុងមាត្រា ២ នៃអនុសញ្ញានេះ ឬបើប្រទេសនោះកំណត់យកមាត្រា ៣ នៃអនុសញ្ញានេះសម្រាប់មុខរបរនេសាទសមុទ្រ នោះប្រទេសជាសមាជិកនោះនឹងត្រូវចាត់ទុកដោយពេញច្បាប់ថាបានធ្វើអប្បដិបត្តិកម្មអនុសញ្ញាឆ្នាំ១៩៥៩។

(ច) ដោយប្រទេសជាសមាជិកណាមួយដែលជាដៃគូនឹងអនុសញ្ញាឆ្នាំ១៩៦៥ ស្ដីពីអាយុអប្បរមា (ការងារក្រោមដី) និងដោយផ្អែកតាមការកំណត់អាយុអប្បបរមាមិនឱ្យតិចជាងអាយុដែលមានកំណត់នៅក្នុងមាត្រា ២ នៃអនុសញ្ញានេះ ឬបើប្រទេសនោះកំណត់យកអាយុសម្រាប់ការងារក្រោមដីតាមបទបញ្ញត្តិនៃមាត្រា ៣ របស់អនុសញ្ញានេះ នោះប្រទេសជាសមាជិកនោះត្រូវបានចាត់ទុកដោយពេញច្បាប់ថាបានធ្វើអប្បដិបត្តិកម្មអនុសញ្ញាឆ្នាំ១៩៦៥។

៥. ការយល់ព្រមចំពោះកាតព្វកិច្ចនៃអនុសញ្ញានេះ៖

(ក) ត្រូវធ្វើអប្បដិបត្តិកម្មអនុសញ្ញាឆ្នាំ១៩១៩ ស្ដីពីអាយុអប្បបរមា (ការងារឧស្សាហកម្ម) អនុលោមតាមមាត្រា ១២ នៃអនុសញ្ញានេះ។

(ខ) ចំពោះវិស័យកសិកម្ម ត្រូវធ្វើអប្បដិបត្តិកម្មអនុសញ្ញាឆ្នាំ១៩២១ ស្ដីពីអាយុអប្បបរមា (វិស័យកសិកម្ម) អនុលោមតាមមាត្រា ១២ នៃអនុសញ្ញានេះ។

(គ) ចំពោះការងារនៅសមុទ្រ ត្រូវធ្វើអប្បដិបត្តិកម្មអនុសញ្ញាឆ្នាំ១៩២០ ស្ដីពីអាយុអប្បបរមាសម្រាប់ការងារនៅសមុទ្រ ដោយអនុលោមតាមមាត្រា ១០ នៃអនុសញ្ញានេះ ព្រមទាំងអនុសញ្ញាឆ្នាំ១៩២១ ស្ដីពីអាយុអប្បបរមារបស់អ្នករៀបចំនាវា និងអ្នកដុតឡចំហាយក្នុងនាវា ដោយអនុលោមតាមមាត្រា ១២ នៃអនុសញ្ញានេះ។

## មាត្រា ១១

សច្ចាប័នជាផ្លូវការនៃអនុសញ្ញានេះ ត្រូវជូនដំណឹងទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារដើម្បីចុះបញ្ជិកា។

## មាត្រា ១២

១. អនុសញ្ញានេះត្រូវចាត់ទុកជាកាតព្វកិច្ចចំពោះតែសមាជិកនៃអង្គការអន្តរជាតិខាងការងារទាំងឡាយណាដែលកាផ្តល់សច្ចាប័នរបស់ខ្លួនត្រូវបានចុះបញ្ជិការួចហើយ ដោយអគ្គនាយកនៃអង្គការនេះ។

២. អនុសញ្ញានេះត្រូវចូលជាធរមានក្នុងរយៈពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការផ្តល់សច្ចាប័នរបស់ប្រទេសជាសមាជិកចំនួនពីរត្រូវបានទទួលការចុះបញ្ជិកាពីអគ្គនាយកនៃការិយាល័យអង្គការអន្តរជាតិខាងការងាររួចហើយ។

៣. បន្ទាប់ពីនោះមក អនុសញ្ញានេះត្រូវចូលជាធរមានសម្រាប់ប្រទេសជាសមាជិកណាមួយក្នុងរយៈពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការផ្តល់សច្ចាប័នរបស់ប្រទេសនោះបានទទួលការចុះបញ្ជិការួចហើយ។

## មាត្រា ១៣

១. ប្រទេសជាសមាជិកណាមួយដែលបានផ្តល់សច្ចាប័នចំពោះអនុសញ្ញានេះរួចហើយ អាចធ្វើអប្បដិបត្តិកម្មវិញបាននៅក្នុងឆ្នាំបន្ទាប់ពីអំឡុងពេលដប់ឆ្នាំបានកន្លងផុត ដោយគិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានលើកទីមួយនៃអនុសញ្ញានេះតាមរយៈលិខិតជូនដំណឹងទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារដើម្បីអគ្គនាយកនេះចុះបញ្ជិកា។ អប្បដិបត្តិកម្មនេះនឹងមិនមានអនុភាពទេរហូតរយៈពេលមួយឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជិកា។

២. ប្រទេសជាសមាជិកណាដែលបានផ្តល់សច្ចាប័នអនុសញ្ញានេះរួចហើយ ប៉ុន្តែនៅក្នុងឆ្នាំបន្ទាប់ពីការផុតរលត់នៃរយៈពេលដប់ឆ្នាំដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ មិនបានអនុវត្តសិទ្ធិនៃអប្បដិបត្តិកម្មដូចដែលបានកំណត់ក្នុងមាត្រានេះទេ នឹងត្រូវរង់ចាំក្នុងរយៈពេលដប់ឆ្នាំថ្មីជាបន្តទៀត។ ហើយបន្ទាប់ពីនោះមក អាចធ្វើអប្បដិបត្តិកម្មក្រោយការកន្លងផុតទៅនៅរៀងរាល់រយៈពេលដប់ឆ្នាំតាមន័យនៃមាត្រានេះ។

## មាត្រា ១៤

១. អគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារត្រូវជូនដំណឹងទៅគ្រប់ប្រទេសជាសមាជិកទាំងអស់នៃអង្គការអន្តរជាតិខាងការងារអំពីការចុះបញ្ជិកានៃរាល់ការផ្តល់សច្ចាប័ន និងអប្បដិបត្តិកម្មរបស់ប្រទេសជាសមាជិកនានានៃអង្គការនេះ។

២. នៅពេលជូនដំណឹងអំពីការផ្តល់សច្ចាប័នទីពីរលើអនុសញ្ញានេះ អគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារត្រូវក្រើនរំលឹកចំពោះប្រទេសជាសមាជិកទាំងអស់នូវកាលបរិច្ឆេទដែលអនុសញ្ញានេះនឹងត្រូវចូលជាធរមាន។

## មាត្រា ១៥

អនុលោមតាមមាត្រា ១០២ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ អគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារត្រូវផ្ញើជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិដើម្បីចុះបញ្ជិកានូវរបាយការណ៍លំអិតអំពីការផ្តល់សច្ចាប័ន និងលិខិតធ្វើអប្បដិបត្តិកម្មដែលបានចុះបញ្ជិកាដោយអគ្គនាយកនេះរួចហើយ ស្របតាមខ្លឹមសារនៃបទប្បញ្ញត្តិនៃមាត្រាខាងលើ។

## មាត្រា ១៦

នៅពេលណាដែលពិនិត្យឃើញថាមានការចាំបាច់ ក្រុមប្រឹក្សាភិបាលនៃអង្គការអន្តរជាតិខាងការងារត្រូវដាក់ជូនសន្និសីទសាកលនូវរបាយការណ៍ស្តីពីដំណើរប្រព្រឹត្តទៅនៃអនុសញ្ញានេះ ព្រមទាំងបញ្ជាក់ពីគោលបំណងនៃការបញ្ចូលទៅក្នុងរបៀបវារៈនៃសន្និសីទនេះនូវបញ្ហាពាក់ព័ន្ធនឹងការធ្វើបុនរាព្រឹត្តទាំងស្រុង ឬដោយផ្នែកខ្លះចំពោះអនុសញ្ញានេះ។

## មាត្រា ១៧

១. ក្នុងករណីដែលសន្និសីទសាកលអនុម័តអនុសញ្ញាថ្មីដែលធ្វើការពិនិត្យឡើងវិញទាំងស្រុង ឬដោយផ្នែកចំពោះអនុសញ្ញានេះ និងវៀវលែងតែអនុសញ្ញាថ្មីនោះមានកំណត់បទប្បញ្ញត្តិផ្សេងពីនេះ៖

(ក) ការផ្តល់សច្ចាប័ននៃសមាជិកណាមួយចំពោះអនុសញ្ញាថ្មីដែលបានធ្វើកាពិនិត្យឡើងវិញហើយនោះ នឹងត្រូវមានន័យពេញលេញតាមច្បាប់ថាប្រទេសជាសមាជិកនោះបានធ្វើអប្បដិបត្តិកម្មចំពោះអនុសញ្ញានេះជាស្វ័យប្រវត្តិ ដោយមិនមានគិតដល់បទបញ្ញត្តិដូចមានចែងក្នុងមាត្រា ១៣ ខាងលើ និងប្រសិនបើក្នុងពេលនោះ អនុសញ្ញាថ្មីនេះត្រូវបានចូលជាធរមានរួចហើយ។

(ខ) ចាប់ពីពេលដែលអនុសញ្ញាថ្មីនោះចូលជាធរមាន អនុសញ្ញានេះនឹងលែងបើកឱ្យប្រទេសជាសមាជិកនានា ផ្តល់សច្ចាប័នទៀតហើយ។

២. ទោះក្នុងករណីណាក៏ដោយ អនុសញ្ញានេះនឹងនៅជាធរមានជាដរាប ទាំងទម្រង់ និងខ្លឹមសារចំពោះប្រទេសជាសមាជិកណាដែលបានឱ្យសច្ចាប័នរួចហើយ ប៉ុន្តែមិនទាន់បានផ្តល់សច្ចាប័នលើអនុសញ្ញាដែលបានពិនិត្យឡើងវិញនៅឡើយ។

## មាត្រា ១៨

អត្ថបទបកប្រែជាភាសាអង់គ្លេស
និងបារាំងនៃអនុសញ្ញានេះមានតម្លៃជាផ្លូវការដូចគ្នា។

********************